ក្រសួងអប់រំរដ្ឋ NSW

School counselling service

Information for parents and carers

# សេវាកម្មប្រឹក្សាយោបល់សាលា

## ព័ត៌មានសម្រាប់ឪពុកម្ដាយ និងអ្នកថែទាំ

សាលារៀនរដ្ឋក្នុងរដ្ឋ NSW ទាំងអស់ មានសិទ្ធិទទួលបានការគាំទ្រផ្នែកចិត្តសាស្ត្រតាមរយៈ សេវាកម្មប្រឹក្សាយោបល់សាលា។

សេវាកម្មប្រឹក្សាយោបល់សាលា រួមមានអ្នកប្រឹក្សាយោបល់សាលា និងអ្នកចិត្តសាស្ត្រ ដែលជាអ្នកផ្ដល់ការប្រឹក្សាយោបល់ ការពិនិត្យវាយតម្លៃផ្នែកចិត្តសាស្ត្រ និងសេវាកម្មអន្តរាគមន៍សម្រាប់សិស្សចាប់ពីសាលាត្រៀម ដល់ថ្នាក់ទី12។ ពួកគេធ្វើការជាមួយក្រុមគ្រួសារ បុគ្គលិកសាលា  និងអ្នកជំនាញផ្សេងទៀតដើម្បីគាំទ្រការរៀនសូត្រ សុខភាពផ្លូវចិត្ត និងតម្រូវការសុខុមាលភាពរបស់សិស្ស ហើយនិងដើម្បីបង្កើតបរិយាកាសរៀនសូត្រប្រកបដោយសុវត្ថិភាព សុខភាពល្អ និងគាំទ្រ។

បុគ្គលិកប្រឹក្សាយោបល់សាលាទាំងអស់ មានសញ្ញាបត្រថ្នាក់ក្រោយបរិញ្ញាបត្រផ្នែកចិត្តសាស្ត្រ ហើយអនុវត្តជំនាញរបស់ពួកគេក្នុងផ្នែកសុខភាពផ្លូវចិត្ត ការរៀនសូត្រ និងអាកប្បកិរិយា ដើម្បីជួយកុមារ និងមនុស្សវ័យក្មេងឱ្យទទួលបានជោគជ័យក្នុងការសិក្សា ខាងសង្គម អាកប្បកិរិយា និងអារម្មណ៍។

អ្នកប្រឹក្សាយោបល់សាលា ឬអ្នកចិត្តសាស្ត្រអាចៈ

- ផ្តល់ជូនការប្រឹក្សាយោបល់សម្រាប់សិស្ស
- ពិនិត្យវាយតម្លៃការរៀនសូត្រ និងតម្រូវការផ្នែកសុខភាពផ្លូវចិត្តរបស់សិស្ស
- ធ្វើការដោយសហការជាមួយគ្រូបង្រៀន និងបុគ្គលិកឯកទេស
- ជួយឱ្យគ្រួសារយល់ដឹង និងគ្រប់គ្រងការរៀនសូត្រ ហើយនិងតម្រូវការផ្នែកសុខភាពផ្លូវចិត្តរបស់កូនៗពួកគេ
- ទំនាក់ទំនងជាមួយទីភ្នាក់ងារខាងក្រៅ និងអ្នកជំនាញផ្នែកសុខភាពផ្លូវចិត្ត ដើម្បីផ្តល់គាំទ្រដោយសម្របសម្រួលមានគោលដៅវិជ្ជមានសម្រាប់សិស្សម្នាក់ៗ។

ពេលធ្វើការជាមួយសិស្ស ឪពុកម្តាយ ឬអ្នកថែទាំ និងគ្រូបង្រៀន បុគ្គលិកប្រឹក្សាយោបល់សាលានឹងពន្យល់ពីរបៀបដែលពួកគេធ្វើការ ស្ដាប់ដោយប្រុងប្រយ័ត្ននូវអ្វីដែលបាននិយាយ ជួយបំភ្លឺពីជម្រើសនានា និងលើកទឹកចិត្តឱ្យមានការសម្រេចចិត្តបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់។

## ការសម្ងាត់

បុគ្គលិកប្រឹក្សាយោបល់សាលា ផ្តល់ជូនការគាំទ្រផ្នែកចិត្តសាស្ត្រដោយស្ម័គ្រចិត្ត និងដោយសម្ងាត់សម្រាប់សិស្ស។ ព័ត៌មានសម្ងាត់នឹងមិនត្រូវបានចែករំលែកទៅអ្នកដទៃ ដោយគ្មានការអនុញ្ញាតពីសិស្ស ឪពុកម្តាយ ឬអ្នកថែទាំទេ លុះត្រាតែតម្រូវដោយច្បាប់ ឬដើម្បីទប់ស្កាត់ហានិភ័យធ្ងន់ធ្ងរដល់សុវត្ថិភាព ឬសុខុមាលភាព។

## ការបញ្ជូនបន្ត

អាទិភាពសម្រាប់ការគាំទ្រប្រឹក្សាយោបល់សាលា ត្រូវបានកំណត់នៅក្នុងការពិគ្រោះយោបល់ជាមួយក្រុមរៀនសូត្រ និងសុខុមាលភាព។ ឪពុកម្តាយ ឬអ្នកថែទាំដែលមានការព្រួយបារម្ភចំពោះការរៀនសូត្រ សុខភាពផ្លូវចិត្ត និង/ឬសុខុមាលភាពរបស់កូនពួកគេ អាចស្នើសុំការណាត់ជួបមួយដោយទាក់ទងទៅសាលារៀន។ សិស្សក៏អាចបញ្ជូនបន្តដោយខ្លួនឯង ឬស្វែងរកជំនួយពីឪពុកម្តាយ ឬបុគ្គលិកបង្រៀន ដើម្បីធ្វើការណាត់ជួបផងដែរ។

## សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមទូរសព្ទទៅសាលារៀន។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ដើម្បីជួយអ្នកក្នុងការសាកសួររបស់អ្នក សូមទូរសព្ទមក សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទលេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។

ប្រាប់ការីទូរសព្ទនូវលេខទូរសព្ទដែលអ្នកចង់ហៅ ហើយការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់ម្នាក់ ដើម្បីជួយអ្នកក្នុងការសន្ទនា។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។